**ម.ម.ជ** បាននឹងកំពុងអនុវត្តការងារត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្រតាមមណ្ឌលពាណិជ្ជកម្ម អង្គភាពសេដ្ឋកិច្ច និងបញ្ជាក់សមត្ថភាពអប្បបរមា និងអតិបរមា អំពីទម្ងន់និង/ឬរង្វាស់រង្វាល់នៃឧបករណ៍មាត្រាសាស្ត្រដែលអនុញ្ញាតឱ្យប្រើប្រាស់ឬកាន់កាប់បានក្នុងសកម្មភាពពាណិជ្ជកម្មវិស័យផ្សេងៗ និងបានត្រួតពិនិត្យទំនិញផលិត និងទំនិញវេចខ្ចប់ ដោយបញ្ជាក់ពីបរិមាណសុទ្ធ និងជានាភាពត្រឹមត្រូវនៃទម្ងន់ និងរង្វាស់រង្វាល់នៅលើសំភារៈវេចខ្ចប់ទំនិញនោះ ឱ្យត្រូវតាមប្រព័ន្ធឯកតាមាត្រាសាស្ត្រជាតិស្របច្បាប់ដូចបានកំណត់ក្នុងឧបសម្ព័ន្ធទី១ និងទី២ នៃច្បាប់ស្តីពីមាត្រាសាស្ត្រ ហើយបានដាក់សញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូង និងសញ្ញាត្រួតពិនិត្យផ្ទៀងផ្ទាត់កំពុងប្រើប្រាស់លើឧបករណ៍មាត្រាសាស្ត្រ។ អនុលោមតាមមាត្រា២៥ នៃច្បាប់ស្តីពី មាត្រាសាស្ត្រ ចែងថា "ឧបករណ៍មាត្រាសាស្ត្រអាចលក់ ឬដាក់តាំងបានលុះត្រាតែឧបករណ៍នោះមានពាណិជ្ជសញ្ញា និងមានការបញ្ជាក់ពីការត្រួតពិនិត្យផ្ទៀងផ្ទាត់លើកដំបូងរបស់មន្ត្រីត្រួតពិនិត្យនៃមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ"។

**ម.ម.ជ** បានផ្តល់អាជ្ញាប័ណ្ណប្រើប្រាស់ពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជាជូនដល់ក្រុមហ៊ុនមួយចំនួនក្នុងព្រះរាជាណាចក្រកម្ពុជា។ ជាមួយនេះផងដែរ **ម.ម.ជ** ក៏មានភារកិច្ចគ្រប់គ្រងលើការចេញអាជ្ញាប័ណ្ណផលិត និងការជួសជុលឧបករណ៍មាត្រាសាស្ត្រដល់អង្គភាពសេដ្ឋកិច្ចដែលពាក់ព័ន្ធផ្នែកមាត្រាសាស្ត្រ។

មជ្ឈមណ្ឌល
មាត្រាសាស្ត្រជាតិ

សញ្ញាត្រួតពិនិត្យ
ដំបូង

សញ្ញាត្រួតពិនិត្យ
កំពុងប្រើប្រាស់

ពាណិជ្ជសញ្ញា
មាត្រាសាស្ត្រកម្ពុជា



សញ្ញាផ្អាកការប្រើប្រាស់

ឧបករណ៍មាត្រាសាស្ត្រមានច្រើនប្រភេទដែលប្រើប្រាស់ក្នុងវិស័យពាណិជ្ជកម្ម សេវាកម្ម សុខភាពសាធារណៈ សេវាកម្ម ប្រៃសណីយ៍ អគ្គិសនី ឧស្ម័ន ទឹក ឧស្សាហកម្ម វិស្វកម្ម ឬវិស័យផ្សេងៗទៀត។













## ទំនាក់ទំនង

អគារលេខ២០៥ ផ្លូវជាតិលេខ៥ សង្កាត់គីឡូម៉ែត្រលេខ៦
ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ

(៨៥៥) ៩៧ ៩៧០ ២០៥៥ / ៩៩ ៤៧០ ០៤២

www.nmc-misti.gov.kh

**ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

MINISTRY OF INDUSTRY, SCIENCE, TECHNOLOGY AND INNOVATION

# មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ (ម.ម.ជ)

# NATIONAL METROLOGY CENTER (NMC)



## សាវតា

- ព្រះរាជក្រមលេខ ២១៥-ប.រ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ១៩៦៤ ស្តីពីការបង្កើតក្រុមទម្ងន់ និងរង្វាស់រង្វាល់។
- ព្រះរាជក្រឹត្យលេខ ៥៣៦-ប.រ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៦៥ ស្តីពីការរៀបចំក្រសួងឧស្សាហកម្ម។
- ត្រូវបានបង្កើតឡើងអង្គភាពមានឈ្មោះថា "ក្រុមហ៊ុនជាតិខាងរង្វាស់រង្វាល់" ស្ថិតក្រោមក្រសួងឧស្សាហកម្ម (ព្រះរាជក្រឹត្យលេខ ៤៣/៦៨-ប.រ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ១៩៦៨) នាសម័យសង្គមរាស្ត្រនិយម ក្រោមព្រះរាជកិច្ចដឹកនាំអតីតព្រះមហាក្សត្រ ព្រះករុណា ព្រះ ទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ (ព្រះបរមរតនកោដ្ឋ) រហូតដល់ឆ្នាំ១៩៧០។
- ឆ្នាំ១៩៨៣ ដល់ឆ្នាំ១៩៨៧ នាយកដ្ឋានកាំកុងត្រូលនៃក្រសួងពាណិជ្ជកម្មរៀបចំការត្រួតពិនិត្យរង្វាស់រង្វាល់និងត្រួតពិនិត្យមុខទំនិញក្នុងស្រុកហើយដល់ឆ្នាំ១៩៩២ ការងារគ្រប់គ្រងទម្ងន់ និងរង្វាស់រង្វាល់ប្រគល់មក ក្រសួងឧស្សាហកម្ម។
- ឆ្នាំ១៩៩៥ បានបង្កើតអង្គភាពមានឈ្មោះ "អង្គភាពទម្ងន់ និងរង្វាស់រង្វាល់" ស្ថិតក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានបច្ចេកទេសនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។
- ឆ្នាំ១៩៩៩ អង្គភាពបានវិវត្តក្លាយជានាយកដ្ឋានមាត្រាសាស្ត្រ ស្ថិតក្រោមអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល តាមរយៈអនុក្រឹត្យលេខ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាលកម្ពុជា។
- ឆ្នាំ២០០៩ព្រះរាជាណាចក្រកម្ពុជាបានបង្កើតច្បាប់ស្តីពីមាត្រាសាស្ត្រដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ០៨០៩/០១៦ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩។
- ឆ្នាំ២០១១ អនុលោមតាមមាត្រា៥ ជំពូកទី២ នៃច្បាប់ស្តីពីមាត្រាសាស្ត្រ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើត **មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ** សរសេរជាអក្សរកាត់ **ម.ម.ជ** ដែលមានឋានៈស្មើ នឹងអគ្គនាយកដ្ឋាន និងមានត្រាសម្គាល់របស់ខ្លួនមួយដោយឡែក ហើយស្ថិតក្រោមក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។
- ចាប់ពីឆ្នាំ២០១៣ តមកមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ ត្រូវបានស្ថិតក្រោមក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រោយមក នៅឆ្នាំ២០២០ ស្ថិតនៅក្រោមក្រសួងឧស្សាហកម្មវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ហើយមាននាយកដ្ឋានក្រោមឱវាទចំនួន ០៤៖
    ១. នាយកដ្ឋានវិទ្យាសាស្ត្រមាត្រាសាស្ត្រ
    ២. នាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ
    ៣. នាយកដ្ឋានមាត្រាសាស្ត្រឧស្សាហកម្ម
    ៤. នាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ

## កិច្ចសហប្រតិបត្តិការអន្តរជាតិ

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានជំរុញសមត្ថកិច្ចគ្រប់គ្រង ដឹកនាំអនុវត្តវិស័យមាត្រាសាស្ត្រប្រកបដោយភាពត្រឹមត្រូវ យុត្តិធម៌ និងភាពជឿជាក់ដើម្បីឱ្យមានការទទួលស្គាល់សមត្ថភាពនៃមន្ទីរពិសោធន៍ព្យាសកម្មកម្រិតអន្តរជាតិ ISO/IEC 17025។ ការធ្វើសុខដុមនីយកម្មជាមួយស្ថាប័នមាត្រាសាស្ត្រក្នុងតំបន់និងអន្តរជាតិ**ម.ម.ជ**បានពង្រឹងសមត្ថភាពរហូតបានចូលជាសមាជិករបស់អង្គការអន្តរជាតិនានាមានដូចជា៖

- ជារដ្ឋសង្កេតការណ៍នៃមហាសន្និបាតទម្ងន់ និងរង្វាស់រង្វាល់ General Conference on Weights and Measures - CGPM
- ជារដ្ឋសមាជិកនៃអង្គការនីត្យានុកូលមាត្រាសាស្ត្រអន្តរជាតិ International Organization of Legal Metrology - OIML
- ជាសមាជិកពេញសិទ្ធិនៃវេទិកានីត្យានុកូលមាត្រាសាស្ត្រតំបន់អាស៊ីប៉ាស៊ីហ្វិក Asia Pacific Legal Metrology Forum - APLMF
- ជាសមាជិកពេញសិទ្ធិនៃកម្មវិធីមាត្រាសាស្ត្រតំបន់អាស៊ីប៉ាស៊ីហ្វិក Asia Pacific Metrology Program - APMP
- ជាសមាជិកក្រុមអ្នកជំនាញមាត្រាសាស្ត្រអាស៊ាន Asean Expert Group on Metrology - AEGM
- ជាក្រុមការងារនៃគណៈកម្មាធិការពិគ្រោះយោបល់ផ្នែកស្តង់ដារ និងគុណភាពអាស៊ាន, ក្រុមការងារផ្នែកនីត្យានុកូលមាត្រាសាស្ត្រ Asean Consultative Committee for Standard and Quality, Working Group on Legal Metrology - ACCSQ/WG3។

ការធ្វើសុខដុមនីយកម្មជាមួយស្ថាប័នមាត្រាសាស្ត្រក្នុងតំបន់ និងអន្តរជាតិ

## សកម្មភាពការងារ

**មាត្រាសាស្ត្រ** សំដៅដល់វិទ្យាសាស្ត្រ និងការគ្រប់គ្រងទម្ងន់ និងរង្វាស់រង្វាល់។

**ម.ម.ជ** មានភារកិច្ចគ្រប់គ្រងនូវរាល់សកម្មភាព និងសេវាពាក់ព័ន្ធនឹងការងារមាត្រាសាស្ត្រជាអាទិ៍ វិទ្យាសាស្ត្រមាត្រាសាស្ត្រ មាត្រាសាស្ត្រឧស្សាហកម្ម និងនីត្យានុកូលមាត្រាសាស្ត្រ។**ម.ម.ជ**បានកសាងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាយ៉ាងច្រើនដែលត្រូវបានប្រើប្រាស់ជាត្រីវិស័យសម្រាប់ពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យមាត្រាសាស្ត្រ។

**ម.ម.ជ** បានខិតខំពង្រឹង និងពង្រីកការផ្តល់សេវាសាធារណៈផ្នែកមាត្រាសាស្ត្ររួមមាន៖ ត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិត និងទំនិញវេចខ្ចប់ ព្យាសកម្ម អនុម័តគំរូ តេស្ត-វិភាគ ចុះបញ្ជីមាត្រាសាស្ត្រ លិខិតអនុញ្ញាតនាំចូលឧបករណ៍មាត្រាសាស្ត្រអាជ្ញាបណ្ណផលិត និង ជួសជុលឧបករណ៍មាត្រាសាស្ត្រ និងការប្រើពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជាដើម្បីធានាឱ្យការធ្វើពាណិជ្ជកម្មមានភាពត្រឹមត្រូវ សុចរិត យុត្តិធម៌សមធម៌ និងធានាប្រយោជន៍រវាងអ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់ ព្រមទាំង សម្រួលដល់ការអភិវឌ្ឍផ្នែកវិទ្យាសាស្ត្របច្ចេកទេសដើម្បីភាពរីកចម្រើន នៃសេដ្ឋកិច្ចជាតិ។
**ម.ម.ជ** បាននឹងកំពុងរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីការអនុវត្តច្បាប់មាត្រាសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការងារមាត្រាសាស្ត្រជូនដល់អាជ្ញាធរមូលដ្ឋាន អាជីវករ និងអង្គភាពសេដ្ឋកិច្ចនានា (ក្រុមហ៊ុន សហគ្រាស រោងចក្រ សិប្បកម្ម) និងប្រជាពលរដ្ឋនៅតាមបណ្តារាជធានី-ខេត្ត។ ទន្ទឹមនឹងនេះ **ម.ម.ជ** បាននឹងកំពុងបើកវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្រ ឱ្យស្របតាមបទដ្ឋានបច្ចេកទេសអន្តរជាតិជូនដល់មន្ត្រីត្រួតពិនិត្យការងារមាត្រាសាស្ត្រនៅតាមមន្ទីរឧ.វ.ប.ន រាជធានី-ខេត្ត ដើម្បីអនុវត្តន៍ការងារជំនាញមាត្រាសាស្ត្រតាមមូលដ្ឋាន។ អនុលោមតាមប្រកាសលេខ១២៣ MIH/2015 ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ ២០១៥ ក្រសួងបានធ្វើប្រតិភូកម្មមុខងារត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្រ ទំនិញផលិត និងទំនិញវេចខ្ចប់ជូនដល់មន្ទីរ ឧ.វ.ប.ន រាជធានី- ខេត្ត ដើម្បីអនុវត្តន៍ការងារជាខ្សែបណ្តោយរបស់ **ម.ម.ជ**។

បច្ចុប្បន្ន **ម.ម.ជ** ធ្វើព្យាសកម្មលើឧបករណ៍មាត្រាសាស្ត្រដល់ម្ចាស់ក្រុមហ៊ុន រោងចក្រ សិប្បកម្ម សហគ្រាស ដោយបញ្ជាក់ពីកម្រិតលំអៀង និងកំពុងធ្វើការអភិវឌ្ឍន៍មន្ទីរពិសោធន៍បន្ថែមទៀតលើផ្នែកម៉ាស សម្ពាធ ចំណុះ ទំហំ និងសីតុណ្ហភាព ដើម្បីទទួលបានស្តង់ដារ ISO/IEC 17025:2017 ក្នុងគោលបំណងគាំទ្រដល់វិស័យឧស្សាហកម្មសហគ្រាសផលិតកម្មក្នុងស្រុក។




